# ឯកឧត្តម ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារគណៈបក្សប្រជាជនកម្ពុជាខេត្តកែប រយៈពេល ០៦ ខែ ឆ្នាំ២០១០ និងទិសដៅភារកិច្ចអនុវត្តបន្ត





ឯកឧត្តម **ចម ប្រសិទ្ធ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានក្រុមការងារចុះជួយខេត្តកែប នៅព្រឹកថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១០ បានអញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារគណៈបក្សបជាជនកម្ពុជា ខេត្តកែប រយៈពេល០៦ខែ ឆ្នាំ២០១០ និងទិសដៅភារកិច្ចអនុវត្តបន្ត ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងសមាជិក សមាជិការ នៃក្រុមការងារគ្រប់លំដាប់ថ្នាក់របស់គណៈបក្សប្រជាជនកម្ពុជា ប្រចាំខេត្តកែប ។

ឯកឧត្តម **សំ សារិន** សមាជិកគណៈកម្មាធិការកណ្តាល អនុប្រធានប្រចាំការ និងជាប្រធានក្រុមប្រឹក្សាខេត្តកែប បានអានរបាយការណ៍បូកសរុបលទ្ធផលការងាររយៈពេល០៦ ខែ ឆ្នាំ២០១០ ស្តីពីការងាសន្តិសុខសណ្តាប់ ធ្នាប់សង្គម-ការងារសេដ្ឋកិច្ច និងជីវភាព និងការងាររៀបចំរចនាសម្ព័ន្ធបក្ស ដែលពិនិត្យជារួម បានធ្វើការកត់ សំគាល់ថាៈ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់គណៈកម្មាធិការកណ្តាលគណៈបក្សប្រជាជនកម្ពុជា និងបានការជួយឧបត្ថម្ភគាំទ្រ ទាំងស្មារតី សំភារៈ ថវិកា ពីសំណាក់ក្រុមការងារចុះជួយខេត្តកែប ដែលមានឯកឧត្តម **ចម ប្រសិទ្ធ** ជាប្រធាន គួបផ្សំនិងគំនិតច្នៃប្រឌិតរបស់គណៈបក្សខេត្ត ធ្វើឱ្យខេត្តកែបបច្ចុប្បន្ន មានការប្រែប្រួលរីកចំរើនលើ គ្រប់វិស័យ ជាពិសេសលើការងារស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ។ ដោយឡែកចំពោះការកសាងកំលាំង បក្ស ខេត្តកែបសំរេចបានជោគជ័យដ៏ធំធេង ធ្វើឱ្យប្រជាជន មហាជនកាន់តែមានជំនឿទុកចិត្ត បង្កើនការគាំទ្រ និងចូលរួមយ៉ាងសកម្មរាល់ការងាររបស់បក្ស។

បន្ទាប់ពីអង្គប្រជុំ បានតាមដានស្តាប់របាយការណ៍ និងសំណូមពររបស់ប្រធានក្រុមការងារ ឃុំ-សង្កាត់ទាំង០៥ នៃខេត្តកែប រួចមក ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់**សម្តេចប្រមុខថ្នាក់ដឹកនាំទាំងបីរបស់គណបក្សប្រជាជនកម្ពុជា** ជូនចំពោះបងប្អូនប្រជាពលរដ្ឋខេត្តកែបទាំងមូល និងវាយតំលៃខ្ពស់ចំពោះលទ្ធផលនៃរបាយការណ៍ការងារក្នុងឆមាសទី១ ឆ្នាំ២០១០ របស់គណបក្សខេត្តដែលសម្រេចបានគួរជាទីមោទនៈ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានជំរុញឱ្យគណៈបក្សខេត្ត យកចិត្តទុកដាក់ចំពោះកំលាំងយុវជន និងស្ត្រី ដែលជាមូលដ្ឋានរឹងមាំមួយនៃការកសាងកំលាំងគណៈបក្ស ហើយក្រុមការងារទាំងអស់ត្រូវចុះឱ្យដល់ មូលដ្ឋាន ដើម្បីក្តាប់ឱ្យបានពីសុខទុក្ខ និងតំរូវការពិតរបស់ប្រជាពលរដ្ឋ និងពិនិត្យឡើងវិញ ថាតើយើងនៅមាន ជំពាក់ការសន្យាជាមួយប្រជាពលរដ្ឋដែរឺទេ ? ពីព្រោះគណបក្សប្រជាជនកម្ពុជា មានប្រពៃណី

ហ៊ានសន្យាគឺ ហ៊ានធ្វើ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានធ្វើការកោតសរសើរ ចំពោះអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ក៏ដូចជាក្រុម ការងារចុះជួយខេត្តកែប ដែលបានខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរបស់ខេត្តឱ្យមានលក្ខណៈរីក ចំរើនឆាប់រហ័ស ជាពិសេសថ្មីៗនេះ ខេត្តបានកសាង សួនច្បារសាធារណៈនៅប្រឫបមាត់ឆ្នេរយ៉ាងស្រស់ស្អាត ដោយមានដាក់តាំងរូបសំណាកផ្សេងៗ បំពាក់គោមភ្លើង ដាក់បង់ និងខ្ទះសម្រាប់ការអង្គុយកំសាន្តរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ ដែលធ្វើឱ្យខេត្តកែបមានទីតាំងកំសាន្តសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍កាន់តែច្រើនឡើង។ ជាមួយគ្នានេះ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានក្រុមការងារចុះជួយខេត្តកែប បានស្នើឱ្យអាជ្ញាធរខេត្ត រកទីតាំងបណ្តុះកូនឈើ ដើម្បអនុវត្តការដាំដើមឈើតាមតំបន់ភ្នំ និងទីសាធារណៈឱ្យមានភាពស្រស់បំព្រងថែមទៀត ពីព្រោះខេត្តកែបមិនមែនគ្រាន់តែជាខេត្តទេសចរណ៍មាត់ឆ្នេរ និងតំបន់កោះប៉ុណ្ណោះទេ តែគឺជាខេត្ត មានសក្តានុពលផ្នែកទេសចរណ៍ធម្មជាតិ និង និងជ្រលងភ្នំផងដែរ ។ ដោយឡែកទាក់ទងនិងមូនិធិសឹង្គសង្គ្រោះ ដែលក្រុមការ ងារចុះជួយខេត្តកែបបានអនុវត្តជាដរាបមក ទៅលើការជួយឧបត្ថម្ភដល់សមាជិកគណបក្សប្រជាជនកម្ពុជា ដែល ទទួលមរណៈភាព និងរៀបអាពាហ៏ពិពាហ៏នោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានស្នើឱ្យក្រុមការងារបន្តអនុវត្តកិច្ចការនេះឱ្យកាន់តែមានភាពរលូនឡើង ។

ស្ថិតក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានសន្យាផ្តល់ កំព្យូទ័រ០១គ្រឿង ម៉ាស៊ីន Printer០១ គ្រឿង និងមានស៊ីនថតរូប ឌីជីថល ០១គ្រឿង ដល់ស្នងការដ្ឋាននគរបាលខេត្តកែប ដើម្បីបំរើការងាររដ្ឋបាលរបស់ខ្លួន ។

តមក ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងគណៈប្រតិភូអមដំណើរ បានអញ្ជើញចុះពនិត្យជាក់ស្តែង ពីដំណើរការអភិវឌ្ឍន៍របស់ខេត្ត ដូចជាៈ ការសាងសង់មន្ទីរ អង្គភាពនានា- ផ្លូវថ្នល់ និងការសាងសង់របងដីឡូតិ៍ របស់ម្ចាស់កម្មសិទ្ធិ ដែលមានមូលដ្ឋានក្នុងខេត្តកែប ។